# ១៥ឆ្នាំកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស : កម្ពុជាដើរទៅមុខ តែនៅមានបញ្ហាច្រើន

ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០០៦ កន្លងទៅនេះគឺជាទិវារំលឹកខួបអនុស្សាវរីយ៍ឆ្នាំទី១៥ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយជម្លោះរួមមួយនៅកម្ពុជា ឬហៅកាត់ថា "កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស" ។ ការសង្កេតឃើញថា សារសំខាន់នៃការរំលឹកទិវានេះជារៀងរាល់ឆ្នាំកន្លងមក នៅមានសភាពចម្រូងចម្រាស់ ហើយនៅឆ្នាំនេះទៀតសោត រាជរដ្ឋាភិបាលកម្ពុជាក៏បានសម្រេចប្រារព្ធឡើងវិញ បន្ទាប់ពីការរំលឹកខួបឆ្នាំទី១០ កាលពីលើកមុន នូវថ្ងៃដ៏មានសារសំខាន់ចំពោះប្រវត្តិនយោបាយចុងក្រោយរបស់ប្រទេសកម្ពុជា ក្នុងបំណងរំលឹកនូវថ្ងៃនៃការចាប់ផ្តើមការកសាងសន្តិភាពនៅប្រទេសកម្ពុជា ក៏ដូចជាដើម្បីប្រមើលសមិទ្ធផល កង្វះខាត និងព្យាយាមស្វែងរកចក្ខុវិស័យទៅថ្ងៃអនាគតទៀត ។

ដោយរំលឹកឡើងវិញនូវកិច្ចព្រមព្រៀងសន្តិភាពនេះ គេមើលឃើញថា វាជាឯកសារប្រវត្តិសាស្ត្រនៃការរួបរួមរបស់ខ្មែរ ជាឯកសារមូលដ្ឋាន និងអាចនិយាយបានថា ជាគ្រឹះចាប់ផ្តើមនៃការស្វែងរកសន្តិភាព ក៏ដូចជាការកសាងប្រទេសកម្ពុជាឡើងវិញ ហើយបានផ្តោតលើចំណុចសំខាន់ៗ ដែលតម្រូវឱ្យមានការគោរពពីសំណាក់គ្រប់ភាគីនយោបាយនៅកម្ពុជា ។ យ៉ាងណាក៏ដោយ មកទល់នឹងបច្ចុប្បន្ននេះ ការសង្កេតមើលឃើញថា មានមតិខ្វែងគ្នាលើការប្រមើលមើល និងលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនាពេលកន្លងមក ។ ជាក់ស្តែង នៅក្នុងការរៀបចំការប្រារព្ធទិវារំលឹកខួបលើកទី១៥នាពេលនេះ ទំនងជាមានភាពមិនស៊ីសង្វាក់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងស្រុក ហើយជាចុងបញ្ចប់ មានតែរាជរដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ តាមរយៈវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានប្រារព្ធពិធីរំលឹកខួបនេះ ជាមួយនឹងការចូលរួមជាកិត្តិយសពីសំណាក់តំណាងអង្គការសហប្រជាជាតិ និងតំណាងប្រទេសមហាអំណាចជាហត្ថលេខីនៃកិច្ចព្រមព្រៀងមួយចំនួន ក្នុងនាមជាវាគ្មិន និងអ្នកចូលរួម ។ គួរឱ្យកត់សម្គាល់ថា នៅក្នុងវេទិកាចំហរធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជានាពេលនោះ មិនបានអញ្ជើញវាគ្មិនដែលជាភាគីមកពីគ្រប់មជ្ឈដ្ឋាននយោបាយ ក្រៅតែមកអំពីសមាជិករដ្ឋាភិបាលមាននិន្នាការខាងគណបក្សនយោបាយដឹកនាំអំណាចតែប៉ុណ្ណោះ ប៉ុន្តែបានអញ្ជើញគ្រប់ភាគីពាក់ព័ន្ធគ្រប់និន្នាការនយោបាយឱ្យចូលរួមនៅក្នុងវេទិកានោះ ។ ហើយ ការរៀបចំរបស់ក្រុមអង្គការមិនមែនរដ្ឋាភិបាលដែលសម្របសម្រួលដោយមូលនិធិបវរសេដ្ឋា ស៊ីន សាន ត្រូវបានខកខានទៅវិញ ដោយសារគ្មានមូលនិធិគ្រប់គ្រាន់សម្រាប់ដំណើរការ ។ ដោយឡែក ក៏មានការរៀបចំដោយឡែកមួយទៀតធ្វើឡើងនៅប្រទេសជប៉ុនដើម្បីប្រារព្ធពិធីរំលឹកខួបកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដូចគ្នានេះដែរ ។

ចំពោះការសង្កេតមើលទៅលើលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនេះវិញ ជារួមឃើញថា រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) ដែលជាភាគីសំខាន់មួយនៃកិច្ចព្រមព្រៀងនេះ (អតីតភាគីរដ្ឋកម្ពុជា) បានផ្តល់នូវមោទនភាព និងសុទិដ្ឋិនិយមជាច្រើន ប៉ុន្តែផ្ទុយទៅវិញ គណបក្ស

ជំទាស់បច្ចុប្បន្នមើលឃើញថា ប្រទេសកម្ពុជាបានបោះមួយជំហានទៅមុខ ហើយថយក្រោយពីរជំហានជានិច្ច ក្នុងការពង្រឹងសន្តិភាព និងស្តារកសាងកម្ពុជាលើមាគ៌ាប្រជាធិបតេយ្យ និងអភិវឌ្ឍន៍។ ចំពោះមតិសាធារណជនវិញ ប្រជាពលរដ្ឋភាគច្រើនហាក់យល់ឃើញថា រាជរដ្ឋាភិបាលកម្ពុជាមិនផ្តល់តម្លៃខ្ពស់ដល់ថ្ងៃ២៣ តុលានេះទេ ហើយបានបំភ្លេចតាមការលុបចេញថ្ងៃនេះពីប្រក្រតីនៃថ្ងៃឈប់សម្រាកអបអររបស់ប្រទេស។

ទិវានៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ធ្វើឱ្យកម្ពុជារំលឹកឡើងវិញនូវតួនាទីដ៏សំខាន់បំផុតនៃសហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ ក៏ដូចជាអ្នកនយោបាយគ្រប់ភាគីនយោបាយ ដែលសុទ្ធតែប្រកបដោយឆន្ទៈបញ្ចប់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃនៅកម្ពុជា ហើយកសាងសន្តិភាពទូទាំងប្រទេស ក៏ដូចជានៅក្នុងតំបន់។ ដំណើរការនេះត្រូវបានបន្តបញ្ចប់ដោយជោគជ័យពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៨ ដោយទទួលបានការបង្រួបបង្រួមឯកភាពជាតិ និងការបង្កើតសន្តិភាពរបស់ជាតិជារួមពេញបរិបូរណ៍។ ទោះយ៉ាងណា ការត្រឹមតែរំលឹកឡើងវិញនូវតួនាទីប្រកបដោយមោទនភាពនេះ នៅមិនទាន់គ្រប់គ្រាន់ទេ ដោយប្រទេសកម្ពុជា និងប្រទេសជាហត្ថលេខីជាចាំបាច់ត្រូវគោរពអនុវត្តតាមខ នៃកិច្ចព្រមព្រៀងនេះ។ និងដោយឡែក សម្រាប់រាជរដ្ឋាភិបាលកម្ពុជាផ្ទាល់ខ្លួនឯងតែម្តង នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដូចដែលប្រសាសន៍របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ឱ្យដឹងថា *"....យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាពីមួយអាណត្តិទៅមួយអាណត្តិបានទទួលស្គាល់យ៉ាងច្បាស់នូវកង្វះខាត និងបញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងដំណើរការអភិវឌ្ឍប្រទេស តាមបែបប្រជាធិបតេយ្យក្មេងខ្ចីរបស់កម្ពុជាមួយនេះ ហើយខិតខំកែលំអរ និងបំពេញកង្វះខាតទាំងនេះ។ ជារួម នៅមានការងារជាច្រើនទៀត ដែលរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជាគ្រប់ស្រទាប់សង្គម និងផ្នែកឯកជននៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ត្រូវរួមគ្នាដោះស្រាយដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅរកកិច្ចអភិវឌ្ឍន៍ និងវិបុលភាព។"*[១] វាជាការចាំបាច់បំផុត ដែលរាជរដ្ឋាភិបាលគប្បីយកចិត្តទុកដាក់ឱ្យបានច្រើនថែមទៀត លើបញ្ហាប្រឈមនៅបច្ចុប្បន្នភាពនេះ ជាមួយនឹងមោទនភាពរបស់ខ្លួនទៅលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ជាពិសេស ត្រូវស្វែងរកសន្តិភាព និងសន្តិសុខទាំងផ្លូវកាយ និងផ្លូវចិត្តឱ្យបានដល់ប្រជាពលរដ្ឋខ្មែរជាអតិបរមា តាមរយៈការជំរុញប្រព័ន្ធទ្រទ្រង់សង្គម ការផ្តល់សេវាសាធារណៈដែលនៅមានកម្រិតទាបនៅឡើយ អយុត្តិធម៌សង្គមដែលគម្រាមកំហែងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងការកាត់បន្ថយគម្លាតរវាងអ្នកមាន និងអ្នកក្រ។

បើទោះបីជាវិបត្តិនយោបាយធ្ងន់ធ្ងរ ហិង្សាត្រូវបានដោះស្រាយជាបន្តបន្ទាប់ តែមានការកត់សម្គាល់មួយតាមរយៈសេចក្តីថ្លែងការណ៍រួមមួយរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ[២] ដែលឱ្យបានដឹងថា ជារួម ប្រទេសកម្ពុជាស្ថិតនៅជាប្រទេសមានវិបត្តិបញ្ហាសេដ្ឋកិច្ច-សង្គមនៅឡើយ។ ប្រជាពលរដ្ឋចំនួនពីរភាគបីនៅមានកង្វះខាតការប្រើប្រាស់ទឹក

---

[១] ថ្លែងក្នុង "វេទិកាបណ្ឌិតសភាចំហ" ដើម្បីរំលឹកខួបលើកទី១៥នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះនៅកម្ពុជា វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ សណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។

[២] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម សមាគមអាដហុក ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ជំនួយផ្នែកច្បាប់នៃកម្ពុជា និងអង្គការម៉ារីណុល (Maryknoll NGO) ដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍ លេខ ២១ តុលា ២០- វិច្ឆិកា ២ ឆ្នាំ២០០៦។

ស្អាតអាចផឹកបាន អត្រាការឆ្លងមេរោគហ៊ីវនៅមានកម្រិតខ្ពស់បំផុតនៅក្នុងតំបន់ ហើយកុមារមានចំនួនតែ ៦០% ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀន។ ប្រជាពលរដ្ឋចំនួន ៣ភាគ៤ រស់នៅក្រោមចំណូល ២ ដុល្លារអាមេរិចក្នុង១ថ្ងៃ។ ស្ទើរតែពាក់កណ្តាលនៃប្រជាពលរដ្ឋកម្ពុជាទាំងអស់ ខ្វះខាតជីវជាតិចំណីអាហារ តែបច្ចុប្បន្ននេះ ២ភាគ៣នៃប្រជាជនទទួលផលប្រយោជន៍ពីជីវជាតិអាហារសមរម្យ។ កាលពី១៥ឆ្នាំមុន អាយុអតិបរមាជាមធ្យមត្រឹមតែ៤០ឆ្នាំ ប៉ុន្តែកុមារដែលមានកំណើតនៅបច្ចុប្បន្ននេះ អាចរស់នៅរហូតដល់អាយុ ៥៦ឆ្នាំ ជាមធ្យម។ នៅឆ្នាំ១៩៩១ មានតែមនុស្សពេញវ័យចំនួន៦០% ប៉ុណ្ណោះ ដែលជាអក្ខរជន ប៉ុន្តែបច្ចុប្បន្នអត្រានេះកើនឡើងដល់ ៧៤%។ សេដ្ឋកិច្ចជាតិកើនឡើងយ៉ាងរឹងមាំក្នុងអត្រា ៤% ជាមធ្យមក្នុង១ឆ្នាំ។ បញ្ហានៃអំពើពុករលួយក្នុងវិស័យតុលាការនៅតែជាបញ្ហាចម្បង ហើយរាជរដ្ឋាភិបាលមិនទាន់បាន អនុម័តបានសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយនៅឡើយ។ លើសពីនេះទៀត ដូចដែលលោកតំណាងពិសេស លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក យ៉ាស៊ី ហ្គៃ បានកត់សម្គាល់នៅ ក្នុងសេចក្តីថ្លែងការណ៍មួយជូនចំពោះក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិថា *"ខ្ញុំទទួលស្គាល់នូវភាពរីកចម្រើន ដែលសម្រេចបាននៅក្នុងការកសាងកម្ពុជាឡើងវិញ។ ទោះបីយ៉ាងណា ១៥ឆ្នាំបន្ទាប់ពីការអនុម័តយកកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បទបញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅមិនទាន់ត្រូវបានបំពេញនៅឡើយ។"* លោក ហ្គៃ បានបន្តសង្កេតឃើញថា ប្រសិនបើអ្វីៗត្រូវធ្វើឱ្យប្រសើរឡើង ការផ្លាស់ប្តូរត្រូវតែចាប់ផ្តើមជាមួយរដ្ឋាភិបាលកម្ពុជា។

ជារួម ទោះបីជាការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅមានការខ្វះចន្លោះនៅឡើយ កិច្ចព្រមព្រៀងនេះជាលិខិតូបករណ៍សំខាន់ដែលបានចាប់ផ្តើមទំព័រសន្តិភាពនៅប្រទេសកម្ពុជា។ ជាពិសេស ដោយឆ្លុះបញ្ចាំងមើលពីរយៈពេល១៥ឆ្នាំកន្លងមក នៅក្នុងទាំងវេទិកាចំហរនៅក្នុងស្រុក ក៏ដូចជាកិច្ចប្រជុំនៅទីក្រុងតូក្យូប្រទេសជប៉ុន លើទិវារំលឹកខួបកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនេះ ការសង្កេតរកឃើញថា ទាំងរាជរដ្ឋាភិបាលកម្ពុជា ទាំងប្រទេសជាអតីតហត្ថលេខីនៃកិច្ចព្រមព្រៀង ទាំងសហគមន៍អន្តរជាតិពាក់ព័ន្ធ សុទ្ធតែបានទទួលស្គាល់នូវចំណុចទាំងវិជ្ជមាន និងអវិជ្ជមាន ដែលត្រូវពង្រឹងបន្ថែម ពិសេសចំណុចពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងបញ្ហាសង្គមជាច្រើនទៀតនៅកម្ពុជា ដែលនៅមានការងារជាច្រើនទៀតត្រូវការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ប្រជាពលរដ្ឋកម្ពុជា និងម្ចាស់ជំនួយ។

ដោយឡែកនៅក្នុងកិច្ចប្រជុំនៅឯទីក្រុងតូក្យូទៅលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនេះ ក្រុមគណៈប្រតិភូតំណាងអង្គការសង្គមស៊ីវិលប្រទេសកម្ពុជា បានផ្តល់ជាអនុសាសន៍សំខាន់ដោយផ្តោតទិសដៅជំនួយអភិវឌ្ឍន៍ផ្លូវការលើកម្ពុជាបន្ថែមទៀត ទៅលើ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការយកចិត្តជំនួយនេះគួរតែជំរុញឱ្យមានជាលក្ខណៈនិរន្តភាព ហើយថែមទាំងជំរុញឱ្យប្រទេសជប៉ុនមិនត្រឹមតែផ្តល់ជំនួយជាថវិកា ប៉ុន្តែថែមទាំងផ្តល់ជំនួយជាជំនាញបច្ចេកទេស និងចូលរួមជំរុញឱ្យផ្តល់យោបល់សម្រាប់ឱ្យមានការផ្លាស់ប្តូរសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខុមហ្វ្រែល អ្នកឃ្លាំមើល ថ្ងៃសុក្រ ទី២៧ ខែតុលា ឆ្នាំ២០០៦